ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ......................................

*រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤*

**សូមគោរពជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់,**

**កម្មវត្ថុ:** គោរពស្នើសុំរៀបចំក្រុមកីឡាបាល់ទាត់ប្រចាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីចូលរួមប្រកួតកីឡាបាល់ទាត់ពានរង្វាន់ "មិត្តភាពយុវជនអន្តរក្រសួង-ស្ថាប័ន" លើកទី២ ឆ្នាំ២០១៤

**យោង:** លិខិតរបស់គណៈកម្មការប្រតិបត្តិកីឡាបាល់ទាត់យុវជនអន្តរក្រសួង-ស្ថាប័ន នៃសហភាពសហព័ន្ធយុវជនកម្ពុជាលេខ០០២/១៤ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** ដើម្បីរៀបចំនូវក្រុមកីឡាបាល់ទាត់ប្រចាំក្រសួងឧស្សាហកម្ម និងសិប្បកម្មដើម្បីចូលរួមប្រកួតកីឡាបាល់ទាត់ពានរង្វាន់ "មិត្តភាពយុវជនអន្តរក្រសួង-ស្ថាប័ន" លើកទី២ ឆ្នាំ២០១៤ ដែលគ្រោងនឹងចាប់ផ្តើមពីថ្ងៃទី២២ ខែវិច្ឆិកា ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ខាងមុខនេះ ។ គោលបំណងនៃការប្រកួតនេះ គឺធ្វើឡើងក្នុងគោលដៅលើកកម្ពស់ស្មារតីយុវជនឲ្យចេះស្រលាញ់ និងលេងកីឡាព្រមទាំងផ្សារភ្ជាប់នូវចំណងសាមគ្គីភាព មិត្តភាព និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងមន្ត្រីរាជការជាយុវជននៃបណ្តាក្រសួង-ស្ថាប័នទាំងអស់ ។

សេចក្តីដូចបានគោរពជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាព និងអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ ។

**ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ**

**រដ្ឋលេខាធិការ**

អនុញ្ញាត
០៦/១០/១៤

**ហេង សុខគង់**